**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១០៤ ប្រក

ថ្ងៃពុធ ៥រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ២០២១

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មបៀរហ្គាឌិន

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងលើកកម្ពស់សុវត្ថិភាពទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានសុវត្ថិភាពទេសចរណ៍ដល់អាជីវកម្មបៀរហ្គាឌិន។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់អាជីវកម្មបៀរហ្គាឌិន ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

លក្ខខណ្ឌវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន ក្នុងដំណាក់កាលការឆ្លងរាលដាលនៃជំងឺឆ្លងកូវីដ-១៩ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ៥.-**

អាជីវកម្មបៀរហ្គាឌិន ដែលអនុវត្តត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ១ នឹងទទួលបាន "លិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មបៀរហ្គាឌិន ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន" ដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

អាជីវកម្មបៀរហ្គាឌិន ដែលអាចចាត់ទុកថាអនុវត្តត្រឹមត្រូវតាម "វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន" បានលុះត្រាតែៈ

- អាជីវកម្មអនុវត្តបានចាប់ពី៨០%ឡើង នៃពិន្ទុសរុប និង
- បំពេញបានគ្រប់ចំណុចតម្រូវចាំបាច់ទាំងអស់។

**ប្រការ៦.-**

ប្រតិបត្តិករទេសចរណ៍ ដែលមានបំណងប្រកបអាជីវកម្មបៀរហ្គាឌិន ឬបន្តអាជ្ញាបណ្ណទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ នៅអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានីខេត្ត ដូចមានកំណត់ក្នុងប្រកាសលេខ០៤៥ ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងទេសចរណ៍ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅឱ្យរដ្ឋបាលរាជធានីខេត្ត។

វិធានសុវត្ថិភាពទេសចរណ៍នេះ ត្រូវបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ច និងជាលក្ខខណ្ឌបន្ថែមក្នុងការស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍។

**ប្រការ៧.**-

អាជីវកម្មបៀរហ្គាឌិន ដែលបានបិទផ្អាកសកម្មភាពដោយរដ្ឋបាលរាជធានីខេត្តក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ ហើយមានបំណងប្រកបអាជីវកម្មបៀរហ្គាឌិនឡើងវិញ ត្រូវដាក់ពាក់ស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី ដែលមានសុពលភាពរយៈពេល១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំបានពេញលេញ ស្របតាមបែបបទ និងនីតិវិធីស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី។

**ប្រការ៨.**-

អាជីវកម្មបៀរហ្គាឌិន ដែលគ្មានលិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មបៀរហ្គាឌិន ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន និងអាជីវកម្មបៀរហ្គាឌិនដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន នឹងក្លាយជាកម្មវត្ថុនៃការព្យួរអាជ្ញាបណ្ណជាបន្ទាន់ ស្របតាមមាត្រា៤៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ៩.**-

វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិននេះ ត្រូវបានដាក់ឱ្យអនុវត្តក្នុងដំណាក់កាលទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ហើយអាចនឹងបន្តក្នុងដំណាក់កាលបន្តទៀតតាមការចាំបាច់។

**ប្រការ១០.**-

ជនណាដែលក្លែងលិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មបៀរហ្គាឌិន ដែលអនុវត្តត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១១.**-

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១២.**-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គាធិការ ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្សាន្ត និងកីឡាទេសចរណ៍ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**<u>កន្លែងទទួល៖</u>**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសុខាភិបាល
-គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-សហព័ន្ធទេសចរណ៍កម្ពុជា
-ដូចប្រការ១២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ១

## នៃប្រកាសលេខ ១០៤ ប្រក .....ចុះថ្ងៃទី ៣ .....ខែ វិច្ឆិកា .....ឆ្នាំ២០ ២១ ......

## ស្តីពី

## "ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន"

| ល.រ | លក្ខខណ្ឌ | ការត្រួតពិនិត្យ | ពិន្ទុ | |
|---|---|---|---|---|
| ១ | **ការរៀបចំនៅច្រកចូល និងទីតាំងចំណតអាជីវកម្មបៀរហ្គាឌិន** | | ចាំបាច់ | ជម្រើស |
| ១.១ | រៀបចំចំណតយានយន្តឱ្យបានត្រឹមត្រូវ និងមានបុគ្គលិក ឬសន្តិសុខប្រចាំការ និងត្រូវពិនិត្យលេខកូដកក់ទុករបស់ភ្ញៀវ មុនអនុញ្ញាតឱ្យចូល (ក្នុងករណីភ្ញៀវកក់ទុកមុន)។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* | |
| ១.២ | មានគំនូសសញ្ញាគម្លាតសុវត្ថិភាពនៅច្រកចូល និងមានបុគ្គលិកប្រចាំការវាស់កម្តៅ បាញ់អាល់កុល ត្រួតពិនិត្យប័ណ្ណចាក់វ៉ាក់សាំងរបស់ភ្ញៀវ ណែនាំភ្ញៀវឱ្យចុះឈ្មោះក្នុងប្រព័ន្ធ QR CODE និងមានម៉ាស៊ីនត្រួតពិនិត្យកម្តៅ បាញ់អាល់កុល ឬទូសម្លាប់មេរោគដោយស្វ័យប្រវត្តិ និងត្រូវមានកន្លែង ឬតូបសន្តិសុខនៅច្រកចូល។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* | |
| ១.៣ | រៀបចំច្រកចេញ-ចូលអាជីវកម្មបៀរហ្គាឌិនផ្សេងគ្នា ។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | | ៥ |
| ១.៤ | មានបិទផ្សាយគោលការណ៍ណែនាំជាទម្រង់ Poster ស្តីពីវិធានការសុខាភិបាល និងប្រភេទទណ្ឌកម្មចំពោះការប្រព្រឹត្តល្មើសនឹងគោលការណ៍ណែនាំ ស្តីពីវិធានការការពារជំងឺកូវីដ-១៩ នៅច្រកចូលបរិវេណអាជីវកម្មបៀរហ្គាឌិន។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ៥* | |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **១៥** | **៥** |
| ២ | **ការរៀបចំបរិវេណទទួលទានអាហារ និងភេសជ្ជៈ និងការបម្រើសេវាកម្មភេសជ្ជៈដែលមានជាតិស្រវឹង** | | ចាំបាច់ | ជម្រើស |
| ២.១ | កន្លែងទទួលទានអាហារ និងភេសជ្ជៈ នៅបរិវេណខាងក្រៅអគារ ឬមានខ្យល់ចេញ-ចូល (មិនមែនជាបន្ទប់បិទជិត) និងមានឧបករណ៍សម្លាប់មេរោគក្នុងបរិយាកាស (ស្របតាមបទដ្ឋានត្រឹមត្រូវ) និងត្រូវរៀបចំឱ្យមានច្រកសុវត្ថិភាព (Exit)។ | ☐ ធ្វើបានត្រឹមត្រូវ<br>☐ ធ្វើមិនបាន | ១០* | |

| | | | | |
|---|---|---|---|---|
| ២.២ | រៀបចំតុ កៅអី ទទួលទានអាហារ និងភេសជ្ជៈ ដាច់ពីគ្នាដោយរក្សាគម្លាតសុវត្ថិភាព (១,៥ម៉ែត្រ) ឬខណ្ឌរបាំង ឬរៀបចំជាតូប ឬខ្ទះអង្គុយដាច់ដោយឡែកពីគ្នា។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ១០ |
| ២.៣ | មានបុគ្គលិកប្រចាំការ សម្អាត អនាម័យ ផ្លាស់ប្តូរកម្រាលតុ បាញ់អាល់កុល ឬទឹកសម្លាប់មេរោគ ក្រោយពេលភ្ញៀវចាកចេញ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ២.៤ | កំណត់ចំនួនភ្ញៀវឱ្យសមាមាត្រទៅនឹងទំហំកន្លែងទទួលទានអាហារ និងភេសជ្ជៈមិនឱ្យលើសចំនួនផ្ទុកជាអតិបរមានៅក្នុងកន្លែងទទួលទានអាហារ និងភេសជ្ជៈ ដោយរក្សាគម្លាតតាមការណែនាំរបស់ក្រសួងសុខាភិបាល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ២.៥ | ត្រូវរៀបចំជាបញ្ជីមុខម្ហូបតាមប្រព័ន្ធអេឡិចត្រូនិច ឬមធ្យោបាយណាមួយដែលចៀសវាងមិនឱ្យភ្ញៀវចាប់កាន់ ប៉ះពាល់បញ្ជីមុខម្ហូបបន្តបន្ទាប់គ្នា ឬបាញ់អាល់កុលសម្លាប់មេរោគលើបញ្ជីមុខម្ហូប មុន និងក្រោយពេលភ្ញៀវកាន់ ឬប៉ះពាល់។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ២.៦ | ឆាកប្រគុំតន្ត្រី ឬកន្លែងចាក់ភ្លេងកំដរភ្ញៀវ រក្សាគម្លាតឆ្ងាយពីកន្លែងតុភ្ញៀវទទួលទានអាហារ និងធ្វើការសម្អាត អនាម័យឧបករណ៍តន្ត្រី ឬឧបករណ៍ចាក់ភ្លេង និងមីក្រូហ្វូនជាប្រចាំ មុន និងក្រោយពេលច្រៀង (ប្រសិនបើអាជីវកម្មបៀរហ្គាឌិនមានការប្រគុំតន្ត្រីកំដរភ្ញៀវ)។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ៥ |
| ២.៧ | មានចាក់បញ្ចាំងស្ប៉តវីដេអូខ្លី ស្តីពីវិធានការការពារជំងឺកូវីដ-១៩ ឬវិធានការនានារបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល (ប្រសិនបើអាជីវកម្មបៀរហ្គាឌិន មានបំពាក់ឧបករណ៍បញ្ចាំងស្លាយ ចម្រៀងកំដរភ្ញៀវ)។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **៣៥** | **១៥** |
| ៣ | **ការរៀបចំបន្ទប់ទឹកសាធារណៈ** | | **ចាំបាច់** | **ជម្រើស** |
| ៣.១ | បន្ទប់ទឹកសាធារណៈជាកន្លែងមានខ្យល់ចេញ-ចូល ឬមានឧបករណ៍សម្លាប់មេរោគក្នុងបរិយាកាស (ស្របតាមបទដ្ឋានត្រឹមត្រូវ) និងមានបុគ្គលិកប្រចាំការ និងធ្វើការសម្អាត បាញ់ថ្នាំសម្លាប់មេរោគជាប្រចាំរៀងរាល់ពេលភ្ញៀវចាកចេញ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៣.២ | មានគំនូសសញ្ញាគម្លាតសុវត្ថិភាព នៅខាងមុខបន្ទប់ទឹក និងមានផ្តល់សាប៊ូ អាល់កុល ដែលលាងដៃ ឬទឹកសម្លាប់មេរោគ ក្រដាសអនាម័យ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |

| | | | | |
|---|---|---|---|---|
| | ឬម៉ាស៊ីនសម្ងួតដៃ នៅខាងមុខ និងក្នុងបន្ទប់ទឹក និងមានបិទផ្សាយខ្លឹមសារអំពីរបៀបលាងសម្អាតដៃឱ្យបានត្រឹមត្រូវ។ | | | |
| ៣.៣ | មានខណ្ឌរបាំងក្នុងបន្ទប់ទឹកសម្រាប់បុរស និងឡាបូលាងដៃ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ១០ |
| | **សរុប** | **ពិន្ទុធ្វើបាន........** | **១០** | **១០** |
| **៤** | **ការគ្រប់គ្រងសុវត្ថិភាពភ្ញៀវ** | | **ចាំបាច់** | **ជម្រើស** |
| ៤.១ | ភ្ញៀវទាំងអស់ត្រូវបង្ហាញប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងចុះឈ្មោះក្នុងប្រព័ន្ធ QR CODE មុនអនុញ្ញាតឱ្យចូលបរិវេណបៀរហ្គាឌិន។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៤.២ | លើកទឹកចិត្តភ្ញៀវឱ្យកក់ទុកមុន (Booking Service) តាមទូរស័ព្ទ ឬប្រព័ន្ធអនឡាញ ដើម្បីងាយស្រួលគ្រប់គ្រងចំនួនភ្ញៀវ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ១០ |
| ៤.៣ | ណែនាំភ្ញៀវមិនឱ្យមានការប្រមូលផ្តុំ ជួបជុំ និងចាប់ដៃស្វាគមន៍គ្នា ឬចាប់កាន់វត្ថុផ្សេងៗបន្តគ្នា និងត្រូវពាក់ម៉ាស់គ្រប់ពេលវេលា លើកលែងតែពេលទទួលទានអាហារ និងភេសជ្ជៈ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៤.៤ | កំណត់ពេលវេលាឱ្យភ្ញៀវប្រើប្រាស់សេវាកម្មនៅក្នុងបៀរហ្គាឌិន ដើម្បីផ្តល់ឱកាសឱ្យភ្ញៀវបន្ទាប់ចូលបន្ត។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ៥ |
| | **សរុប** | **ពិន្ទុធ្វើបាន........** | **១៥** | **១៥** |
| **៥** | **ការគ្រប់គ្រងសុវត្ថិភាពបុគ្គលិក** | | **ចាំបាច់** | **ជម្រើស** |
| ៥.១ | បុគ្គលិកទាំងអស់ត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានគ្រប់គ្នា និងគ្រប់ដូសតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៥.២ | បុគ្គលិកទាំងអស់ត្រូវពាក់ប័ណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឬឯកសារបញ្ជាក់ និងមានឯកសណ្ឋានត្រឹមត្រូវ សមរម្យ មានពាក់ម៉ាស់ ស្រោមដៃ (និង/ឬរបាំងមុខ) ជាប់ជាប្រចាំ និងត្រូវលាងសម្អាតដៃជាមួយសាប៊ូ អាល់កុល ដែលលាងដៃ ទឹកសម្លាប់មេរោគឱ្យបានជាប់ជាប្រចាំ ក្រោយពេលបម្រើសេវាកម្ម ឬចាប់កាន់ប៉ះពាល់វត្ថុផ្សេងៗ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៥.៣ | សម្រួលការរៀបចំបដិសណ្ឋារកិច្ចភ្ញៀវនៅច្រកចូលអាជីវកម្ម និងណែនាំបុគ្គលិកមិនឱ្យមានការជួបជុំប្រមូលផ្តុំគ្នាពេលរង់ចាំទទួលភ្ញៀវ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ៥ |

| | | | | |
|---|---|---|---|---|
| ៥.៤ | បុគ្គលិកទាំងអស់ត្រូវទទួលបានការណែនាំ ឬឆ្លងកាត់វគ្គបណ្តុះបណ្តាលអំពីវិធានការការពារជំងឺកូវីដ-១៩ វគ្គបណ្តុះបណ្តាលស្តីពីបដិសណ្ឋារកិច្ច និងគុណភាពសេវាកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យនិងត្រូវធ្វើតេស្តរហ័ស (Rapid Test) រៀងរាល់ពេលមានការសង្ស័យ ឬពាក់ព័ន្ធជាមួយអ្នកផ្ទុកមេរោគកូវីដ-១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **២០** | **៥** |
| **៦** | **យន្តការតាមដានត្រួតពិនិត្យការអនុវត្តរបស់អាជីវកម្មបៀរហ្គាឌិន** | | **ចាំបាច់** | **ជម្រើស** |
| ៦.១ | លើកទឹកចិត្តឱ្យមានការរៀបចំទីតាំងអាជីវកម្មបៀរហ្គាឌិន ស្ថិតក្នុងតំបន់ទីតាំងដែលរដ្ឋបាលរាជធានីខេត្តបានកំណត់ យោងតាមបទប្បញ្ញត្តិជាធរមាន (ប្រសិនបើរដ្ឋបាលរាជធានីខេត្តបានរៀបចំកំណត់តំបន់ទីតាំងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ Entertainment Zoning) ដែលសមស្របតាមស្ថានភាពទីតាំងភូមិសាស្ត្ររបស់រដ្ឋបាលរាជធានីខេត្តនីមួយៗ។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ១០ |
| ៦.២ | អនុវត្តតាមវិធានការ និងសេចក្តីសម្រេចទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៦.៣ | រៀបចំផែនការសុវត្ថិភាពការពារជំងឺកូវីដ-១៩ (Covid-19 Safety Plan) របស់អាជីវកម្មផ្ទាល់ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ៥ |
| ៦.៤ | បង្កលក្ខណៈងាយស្រួល និងតម្រូវឱ្យបុគ្គលិកទាំងអស់ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានគ្រប់គ្នា និងបញ្ចូលទិន្នន័យបុគ្គលិកបានចាក់វ៉ាក់សាំងទៅក្នុងប្រព័ន្ធចុះឈ្មោះ “ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងវិស័យទេសចរណ៍”។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ១០* | |
| ៦.៥ | មានការលើកទឹកចិត្តភ្ញៀវដែលបានចាក់វ៉ាក់សាំងគ្រប់ដូសតាមការណែនាំរបស់ក្រសួងសុខាភិបាល ដូចជាផ្តល់បណ្ណ័បញ្ចុះតម្លៃ ឬវត្ថុអនុស្សាវរីយ៍។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | | ១០ |
| ៦.៦ | មានរៀបចំបន្ទប់ ឬកន្លែងដាច់ដោយឡែកសម្រាប់បុគ្គលិក ឬភ្ញៀវដែលសង្ស័យផ្ទុកមេរោគកូវីដ-១៩ រង់ចាំមុនពេលទទួលបានការព្យាបាល ឬការធ្វើចត្តាឡីស័ក និងមានគោលនយោបាយគាំទ្រ ឬអនុគ្រោះចំពោះបុគ្គលិកជាប់ចត្តាឡីស័ក ឬត្រូវសម្រាកព្យាបាលជំងឺកូវីដ-១៩។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| ៦.៧ | រៀបចំកន្លែងចម្អិនអាហារឱ្យមានអនាម័យ ស្របតាមគោលការណ៍ណែនាំស្តីពីស្តង់ដាសុវត្ថិភាពម្ហូបអាហាររបស់ក្រសួងសុខាភិបាល។ | □ ធ្វើបានត្រឹមត្រូវ<br>□ ធ្វើមិនបាន | ៥* | |
| | **សរុប** | **ពិន្ទុធ្វើបាន.......** | **៣០** | **២៥** |

“វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន” មាន **២៩ ចំណុច ត្រូវវាយតម្លៃស្មើនឹង ២០០ ពិន្ទុ** ក្នុងនោះអាជីវកម្មត្រូវអនុវត្តចំណុចចាំបាច់មាន **១៩** ចំណុច (**១២៥** ពិន្ទុ) និងចំណុចដែលជាជម្រើសមាន **១០** ចំណុច (**៧៥** ពិន្ទុ) ។

អាជីវកម្មដែលទទួលបានលិខិតបញ្ជាក់ទទួលស្គាល់ជាអាជីវកម្មបៀរហ្គាឌិន ដែលបានអនុវត្តត្រឹមត្រូវតាម **“វិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន”** លុះត្រាតែ

- អាជីវកម្មអនុវត្តបានចាប់ពី ៨០% ឡើង នៃពិន្ទុសរុប និង
- បំពេញបានគ្រប់ចំណុចតម្រូវចាំបាច់ទាំង ១៩ ចំណុច។

លិខិតបញ្ជាក់នេះមានសុពលភាពរយៈពេលអតិបរមា **០១ (មួយ) ឆ្នាំ**។ លិខិតបញ្ជាក់នេះនឹងចាប់រាប់សុពលភាពចាប់ពីកាលបរិច្ឆេទសម្រេចផ្តល់លិខិតបញ្ជាក់ជូន រហូតដល់ការបញ្ចប់សុពលភាពនៅកាលបរិច្ឆេទដូចនឹងកាលបរិច្ឆេទបញ្ចប់សុពលភាពអាជ្ញាបណ្ណទេសចរណ៍ក្នុងឆ្នាំអនុវត្តតែមួយនោះ។

អាជីវកម្មដែលធ្លាប់ទទួលបានលិខិតបញ្ជាក់រួចហើយ នោះការបន្តស្នើសុំវាយតម្លៃ ដើម្បីទទួលបានលិខិតបញ្ជាក់ឆ្នាំអនុវត្តបន្ត គឺចាប់រាប់នៅពេលគាត់ស្នើសុំអាជ្ញាបណ្ណទេសចរណ៍។

ឧបសម្ព័ន្ធ២

នៃប្រកាសលេខ...១០៥ ប្រក.....ចុះថ្ងៃទី...៣.....ខែ...វិច្ឆិកា....ឆ្នាំ២០២១...

ស្តីពី

“ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន”

# លិខិតបញ្ជាក់ទទួលស្គាល់អាជីវកម្មបៀរហ្គាឌិន
# ដែលអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍

Logo
រដ្ឋបាលរាជធានី -ខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី ខេត្ត
លេខ:....................

មន្ទីរទេសចរណ៍រាជធានី ខេត្ត

## លិខិតបញ្ជាក់

ជូន

អាជីវកម្មឈ្មោះ..........................................................................................

អក្សរឡាតាំង..............................................................................................

ដែលបានអនុវត្តស្របតាមវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មបៀរហ្គាឌិន

សុពលភាពគិតចាប់ពីថ្ងៃទី..............................................ដល់ថ្ងៃទី..........................................

ទទួលបានពិន្ទុ....................

ថ្ងៃ.................ខែ...............ឆ្នាំ...............ស័ក ព.ស.២៥.......

ថ្ងៃទី...............ខែ...............ឆ្នាំ...............

អភិបាលរាជធានី ខេត្ត

ប្រធានមន្ទីរទេសចរណ៍

QR-Code

.......................

.......................

*សម្គាល់៖ ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍បន្ត និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់នេះផងដែរ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងទេសចរណ៍

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF TOURISM

CAMBODIA

Kingdom of Wonder

feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០១៧ សណន

ថ្ងៃ ពុធ ១៣រោច ខែ កត្តិក ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០២១

# សេចក្ដីណែនាំ

## ស្ដីពី

## ការអនុវត្តប្រកាសលេខ ១០៨ ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន

ក្នុងគោលបំណងជួយសម្រួលដល់មូលដ្ឋានអាជីវកម្មបៀរហ្គាឌិន ដែលត្រូវបានរាជរដ្ឋាភិបាលអនុញ្ញាតឱ្យបើកដំណើរការឡើងវិញ និងដើម្បីចូលរួមបង្ការ និងរក្សាបាននូវសុវត្ថិភាពទំនុកចិត្ត និងផ្តល់ភាពកក់ក្ដៅជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ព្រមទាំងបុគ្គលិកបម្រើការ និងស្របពេលដែលរាជរដ្ឋាភិបាល បាននឹងកំពុងអនុវត្តយ៉ាងសកម្មនូវយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ និងជំរុញផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទាំងអស់ប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវវិធានការទប់ស្កាត់ការរាលដាលជំងឺកូវីដ-១៩ ក្រសួងទេសចរណ៍បានដាក់ចេញនូវ "**វិធានសុវត្ថិភាពសម្រាប់អាជីវកម្មបៀរហ្គាឌិន**" ដោយភ្ជាប់នូវលក្ខខណ្ឌនៃការអនុវត្តមួយចំនួន ឆ្លើយតបទៅនឹងគន្លងប្រក្រតីភាពថ្មី និងស្ថានភាពនាពេលបច្ចុប្បន្ន។ ការបើកដំណើរការអាជីវកម្មបៀរហ្គាឌិនឡើងវិញនេះ នឹងចូលរួមចំណែកផ្តល់ឱកាសការងារដល់បុគ្គលិកនយោជិត និងរួមចំណែកទ្រទ្រង់វិស័យទេសចរណ៍ និងសេដ្ឋកិច្ចជាតិ ក្នុងដំណាក់កាលរៀនរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងថ្មី។

ក្នុងន័យនេះ ក្រសួងទេសចរណ៍ សូមធ្វើការណែនាំដល់ម្ចាស់អាជីវកម្មបៀរហ្គាឌិនទាំងអស់ ត្រូវយកចិត្តទុកដាក់រៀបចំការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវខ្លឹមសារប្រកាសលេខ ១០៨ ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពី "**ការដាក់ឱ្យអនុវត្តវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន**" ដូចខាងក្រោម៖

១. ត្រូវរៀបចំផែនការកែតម្រូវសម្បទាអាជីវកម្មរបស់ខ្លួនឱ្យស្របនឹងលក្ខខណ្ឌតម្រូវ និងចំណុចណែនាំទាំងឡាយដូចមានកំណត់ក្នុងខ្លឹមសារប្រកាសលេខ ១០៨ ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១។ អាជីវកម្មបៀរ ហ្គាឌិន ត្រូវចាត់ទុកលក្ខខណ្ឌទាំងនោះជាគោលការណ៍ណែនាំចម្បងសម្រាប់ការអនុវត្តក្នុងដំណាក់កាលនេះ និងត្រូវអនុវត្តឱ្យបានហ្មត់ចត់ និងប្រកបដោយស្មារតីទទួលខុសត្រូវ។

២. អាជីវកម្មបៀរហ្គាឌិន ត្រូវរៀបចំឱ្យមានផែនការសកម្មភាពច្បាស់លាស់ ក្នុងការចូលរួមទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន និងត្រូវមានស្មារតីភ្ញាក់រលឹក គិតគូរអំពីបញ្ហាសុវត្ថិភាពភ្ញៀវ សុវត្ថិភាពបុគ្គលិក និងសុវត្ថិភាពសង្គមជាតិជាអាទិភាពចំពោះមុខ ដោយធ្វើការអភិវឌ្ឍ និងគ្រប់គ្រងអាជីវកម្មបៀរហ្គាឌិនក្នុងបរិបថ (គន្លងប្រក្រតីភាពថ្មី)។

៣. អាជីវកម្មបៀរហ្គាឌិន ត្រូវរៀបចំឱ្យមានការបណ្ដុះបណ្ដាលបុគ្គលិកជាប្រចាំ អំពីខ្លឹមសារវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងបណ្ដុះបណ្ដាលស្ដីពីបដិសណ្ឋារកិច្ចល្អ ការពង្រឹងគុណភាពសេវាកម្ម ការបម្រើសេវាកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ។

៤. អាជីវកម្មបៀរហ្គាឌិន ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់នូវវិធានការទាំងឡាយ ដែលដាក់ចេញដោយក្រសួងសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍របស់ក្រសួងទេសចរណ៍ ក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងត្រូវរៀបចំឱ្យមានការបណ្តុះបណ្តាលស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់អាជីវកម្មបៀរហ្គាឌិន ឱ្យបានជាប្រចាំ។

៥. អាជីវកម្មបៀរហ្គាឌិន ត្រូវចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការអនុវត្តគោលនយោបាយនានា ក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ពិសេសគាំទ្រដល់គោលនយោបាយចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែង ដោយជំរុញឱ្យបុគ្គលិកទាំងអស់រួមទាំងក្រុមគ្រួសាររបស់ពួកគាត់ទៅទទួលយកការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ឱ្យបានគ្រប់គ្នា និងឱ្យបានគ្រប់ចំនួនដូសតាមការកំណត់របស់ក្រសួងសុខាភិបាល។

៦. អាជីវកម្មបៀរហ្គាឌិន ត្រូវអនុវត្ត និងប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវគ្រប់ប្រព័ន្ធបច្ចេកវិទ្យាដែលបានដាក់ឱ្យអនុវត្តកន្លងមកដោយរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធរួមមាន៖ ការស្កេន QR Code ទប់ស្កាត់កូវីដ-១៩ និងប្រព័ន្ធ Telegram BOT គ្រប់គ្រងទិន្នន័យភ្ញៀវក្នុងឧស្សាហកម្មទេសចរណ៍ជាដើម។

ទទួលបានសេចក្តីណែនាំនេះ សូម មន្ទីរទេសចរណ៍រាជធានី ខេត្ត និងម្ចាស់អាជីវកម្មបៀរហ្គាឌិន ត្រូវចូលរួមជំរុញការអនុវត្ត សំដៅធានាឱ្យបាននូវការរាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍។

**រដ្ឋមន្ត្រី**

**ថោង ខុន**

<u>កន្លែងទទួល៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
- ឯកសារ កាលប្បវត្តិ